**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធុន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គហេរញ្ញិក
និង នាយក **CCPCR**

កញ្ញា **ស៊ុន ចាន់សែន**
**Miss. SUN Chansen**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Mr. PEUNG Yok Hiep**
នាយិកា **LAC**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គីម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **ស៊ីន សែត**
**Mr. SEN Set**

ស.ប្រ.ក.៣/លេខ ១១/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុង ខេត្ត ប៉ៃលិន

*ភ្នំពេញ, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៩៩នាក់ មកពីគ្រប់ស្រុក និងក្រុងនៅក្នុងខេត្តប៉ៃលិន និងមានសិក្ខាកាមស្រ្តីចូលរួម ប្រមាណ ៣៦% បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍ នៃវិស័យអាទិភាពក្នុងខេត្តប៉ៃលិនកាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៩។

អភិបាលរងខេត្តប៉ៃលិន ឯកឧត្តម **ម៉ី មគ្គ** បានថ្លែងបើកសិក្ខាសាលា ដោយមានការជឿជាក់ថា វិស័យអាទិភាពដែលប្រជាពលរដ្ឋលើកឡើងនឹងមិនឃ្លាតឆ្ងាតពី កម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល។ ហើយបើវិស័យសន្ទស្សន៍ដែលប្រជាពលរដ្ឋលើកឡើងដោយសមស្រប យើងនឹងបោះពួយជំរុញទៅមុខ ។

អ្នកតំណាងរាស្ត្រ អ៊ិច សារូ មណ្ឌលប៉ៃលិន ដែលបានទទួលលទ្ធផលលក្ខខណ្ឌសន្ទស្សន៍នេះបានសន្យាថា *"ខ្ញុំនឹងពាំនាំសំណើទាំងអស់របស់បង ប្អូនបានលើកឡើងជូនរាជរដ្ឋាភិបាល "*។

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងខេត្តប៉ៃលិនដូចខាងក្រោម:

លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តប៉ៃលិនរួមមាន:

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំងដប់នៅក្នុងខេត្ត ប៉ៃលិន** |
|---|
| ១) សុំរកទីផ្សារសេរី សំរាប់លក់ផលិតផលកសិកម្ម ដូចជា ស្រូវ ដំឡូងមី សណ្តែកបាយ ពោត... យ៉ាងហោចណាស់មួយគីឡូក្រាមជាមធ្យមឱ្យបាន ២៥% នៃតម្លៃសាំង ១លីត្រ នៅខេត្តប៉ៃលិន ចាប់ពី ខែ វិច្ឆិកា ឆ្នាំ២០០៩ នេះតទៅ។ |
| ២) សុំឱ្យមានការនាំចេញ ចូល កសិផល និងយកពន្ធតិចជាងតម្លៃបច្ចុប្បន្ន ប្រហែល ៥០% នៅក្នុងខេត្តប៉ៃលិន ចាប់ពីឆ្នាំ២០០៩ នេះតទៅ និងតាមច្បាប់ដែលមានស្រាប់ ។ |

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

៣) ត្រូវឱ្យមានការត្រួតពិនិត្យ និងបណ្តុះបណ្តាល តាមបច្ចេកទេស ដោយមន្ទីរកសិកម្មខេត្ត ។ ពូជដំណាំកសិកម្មដែលនាំចូលអោយមានតម្លៃទាបជាងតម្លៃបច្ចុប្បន្ន ដល់កសិករក្នុងខេត្តប៉ៃលិន ចាប់ពីឆ្នាំ២០១០ នេះតទៅ។

៤) សុំឱ្យមានប្រឡាយទឹក នៅឃុំស្ទឹងត្រង់ ស្រុកសាលាក្រៅដែលប្រឡាយមាន ប្រវែង ៣០គម ទំហំ មាត់លើ ៩ម៉ែត្រ ពីចំណុចភូមិទំនប់ ដល់ទីប្រជុំជនឃុំស្ទឹងត្រង់ ចាប់ពីឆ្នាំ២០១០ ដល់ ២០១២។

៥) សុំ ផ្លូវគ្រួសក្រហម និង ស្ពាន ចំនួន ០៤ខ្សែ ចាប់ពីឆ្នាំ២០១០ ដល់២០១៥

- ទី១ នៅក្នុងសង្កាត់អូរតាវៅ ពីភូមិប៉ាងរលឹម ដល់ភូមិក្រចាប់លើ ប្រហែល ១២គម ។
- ទី២ ក្នុងឃុំអូរអណ្តូងចាប់ភូមិថ្មល់កែង ដល់ភូមិកូនដំរី ឃុំស្ទឹងត្រង់ មានប្រវែងប្រហែល ១៨គម។
- ទី៣ ពីភូមិភ្នំកុយ ដល់ភូមិស្រែអន្ទាក់ ក្នុងឃុំសាលាក្រៅ ប្រវែង ៨គម។
- ទី៤ សុំស្ពានមួយកន្លែងនៅ ភូមិបរតាំងស៊ូ សង្កាត់បយ៉ាខា។

៦) សុំតម្លើងប្រាក់ឧបត្ថម្ភចាប់ពី មេភូមិ មេឃុំ សុំតម្លើងឱ្យបាន ១០០% [ នៃប្រាក់ឧបត្ថមបច្ចុប្បន្ន ]។ សំរាប់មន្ត្រីរាជការ គ្រប់ស្ថាប័នក្នុងខេត្តប៉ៃលិន សុំតម្លើងប្រាក់ខែប្រចាំខែឱ្យបាន ៤០% ជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ២០១០នេះតទៅ។

៧) សុំឱ្យមានឥណទាន ដែលមានការប្រាក់ទាប (១% ក្នុង១ខែ) សំរាប់ប្រជាពលរដ្ឋ ដែលជាកសិករខ្វី នៅក្នុងខេត្ត ប៉ៃលិន ពីឆ្នាំ២០១០ ដល់ ២០១៥។

៨) សុំឱ្យមានការព្យាបាលជំងឺដោយពុំយកកំរៃសេវាព្យាលបាលក្នុងមន្ទីរពេទ្យបង្អែក ក្នុងខេត្តប៉ៃលិន ឬ បញ្ចុះតំលៃ ៥០% ពីតម្លៃបច្ចុប្បន្នឱ្យបាននៅក្នុងឆ្នាំ២០១០។

៩) សុំឱ្យបង្កើតច្បាប់ប្រឆាំងអំពើពុករលួយ ឱ្យបាននៅចុងឆ្នាំ២០០៩ ខាងមុខនេះតទៅ។

១០) សុំតម្លើងប្រាក់បៀវត្សរ៍គ្រូបង្រៀនយ៉ាងតិច ៤០ម៉ឺនរៀលក្នុងមួយខែ បើកឱ្យបានទៀតទាត់ រៀងរាល់ខែ នៅក្នុងខេត្តប៉ៃលិន ចាប់ពីឆ្នាំ២០១០។

គណៈកម្មាធិការខុមហ្វ្រែល សហការជាមួយសមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) និងអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍នៅខេត្តប៉ៃលិនបានផ្តួចផ្តើមធ្វើសិក្ខាសាលានៅខេត្តប៉ៃលិន ដែលក្នុងនោះមានការចូលរួម ពីម្ចាស់ឆ្នោតដែលតំណាងឱ្យសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/និស្សិត កសិករ មកពីស្រុកសាលាក្រៅ និងក្រុងប៉ៃលិន។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣)និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **កុយ ច័ន្ទដារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៩២៥ ៤៤៦